# ការអប់រំ – គោលនយោបាយសង្ខេប ២០១៧

World Vision

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចគួរឲ្យកត់សម្គាល់នូវមូលដ្ឋានគ្រឹះគតិយុត្តិ និងក្របខណ្ឌគោលនយោបាយល្អិតល្អន់ដើម្បីលើកកម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នាក្នុងប្រទេសកម្ពុជា។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ បញ្ហាប្រឈមក្នុងការទទួលបានការអប់រំ គុណភាពអប់រំ និងការអនុវត្តគោលនយោបាយជាច្រើននៅតែមាន។

## អនុសាសន៍សំខាន់ៗ៖

**អង្គការទស្សនៈពិភពលោកសូមធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការ៖**

- បង្កើតនូវក្របខណ្ឌគតិយុត្តិអន្តរក្រសួងសម្រាប់ការអប់រំកុមារតូច ហើយបន្ថែមការគាំទ្រដល់ការអប់រំកុមារតូចឲ្យមានវិសាលភាពធំជាងមុន។
- ធ្វើឲ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងរាប់បញ្ចូលកុមារងាយរងគ្រោះបំផុតរួមទាំងកុមារពិការ តាមរយៈការផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀនអំពីការអប់រំបរិយាប័ន្ន។
- ផ្តោតលើការពង្រឹងជំនាញ និងចំណេះដឹងរបស់គ្រូបឋមសិក្សាក្នុងការបង្រៀនអក្សរនិងលេខមូលដ្ឋានដល់កុមារឲ្យប្រកបដោយប្រសិទ្ធិភាពតាមរយៈការសហការជាមួយអង្គការអន្តរជាតិសម្រាប់ការចេញវិញ្ញាបនបត្រសមមូល ជាផ្នែកមួយនៃគោលដៅរបស់ក្រសួងអប់រំក្នុងការលើកកម្ពស់គុណភាពគ្រូបង្រៀន។
- ធានាថាសាលារៀនជាកន្លែងមានសុវត្ថិភាពសម្រាប់កុមារតាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ *គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន(២០១៦)* និង គោលការណ៍ណែនាំស្តីពី *សាលារៀនសុវត្ថិភាព (២០១៣)*។
- ធ្វើឲ្យមានភាពប្រសើរឡើងនូវ ការឆ្លើយតប និងគណនេយ្យភាពរបស់អ្នកធ្វើការសម្រេចចិត្តថ្នាក់មូលដ្ឋាន ដោយគាំទ្រយ៉ាងពេញទំហឹងនូវការបង្កើនការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម (ISAF) ដែលជាផ្នែកមួយនៃកំណែទម្រង់វិសហមជ្ឈការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

## ស្ថានភាពបច្ចុប្បន្ននៃការអប់រំក្នុងប្រទេសកម្ពុជា

ចាប់តាំងពីប្រទេសកម្ពុជាបានងើបចេញពីរបបបំផ្លិចបំផ្លាញរបស់ខ្មែរក្រហមមក ការកសាងឡើងវិញនូវប្រព័ន្ធអប់រំជាតិគឺជាអាទិភាពរបស់ប្រទេសកម្ពុជា។[1] មាត្រា៦៥ & ៦៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធានាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំមួយដែលមានស្តង់ដារនិងមានគុណភាព។[2] ក្រសួងអប់រំ យុវជន និងកីឡា (អយក) បានធ្វើការសហការយ៉ាងជាប់លាប់ និងយ៉ាងសកម្មជាមួយស្ថាប័នពាក់ព័ន្ធ រួមមានដៃគូរអភិវឌ្ឍន៍ សហគមន៍ និងវិស័យឯកជនដើម្បីអភិវឌ្ឍន៍ប្រព័ន្ធអប់រំសាធារណៈនៅកម្រិតបឋមសិក្សា។[3] ថ្មីៗនេះរាជរដ្ឋាភិបាលកម្ពុជាបានពន្លឿនកំណែទម្រង់វិស័យអប់រំដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០០១មកម្ល៉េះ។[4] កំណែទម្រង់នេះនាំឲ្យមានការអនុម័តគោលនយោបាយ ផែនការសកម្មភាព និងបទដ្ឋានជាច្រើនសំដៅបង្កើនការទទួលបានការអប់រំនិងពង្រឹងគុណភាពអប់រំរួមមាន៖ *ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ដូចជា ផែនការយុទ្ធសាស្រ្តវិស័យអប់រំ (២០១៤-២០១៨) ច្បាប់ស្តីពីការអប់រំ (២០០៧) គោលនយោបាយសាលាកុមារមេត្រី(២០០៧) និង ផែនការគោលសាលាកុមារមេត្រី(២០១៥-២០១៨) គោលនយោបាយស្តីពីការអប់រំកុមារពិការ(២០០៨) គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច(២០១០) ស្តង់ដារបណ្ណាល័យបឋមសិក្សា(២០១១) គោលនយោបាយស្តីពីគ្រូបង្រៀន(២០១៣) និងផែនការសកម្មភាព សម្រាប់គោលនយោបាយស្តីពីគ្រូបង្រៀន(២០១៥)* និង*គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន(២០១៦)*

ជាដើម។ អង្គការទស្សនៈពិភពលោកទទួលស្គាល់នូវវឌ្ឍនភាពទាំងនេះ ប៉ុន្តែបញ្ហាប្រឈមសំខាន់ៗមួយចំនួននៅតែមានដូចជាក្នុងវិស័យអប់រំកុមារតូច ការទទួលបានការអប់រំ និងគុណភាពនៃការអប់រំ។

- **ការអប់រំកុមារតូច**

ការអប់រំកុមារតូចត្រូវបាន រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាជាមធ្យោបាយចាំបាច់ក្នុងការបង្កើនការចូលរៀននៅថ្នាក់បឋមសិក្សា ហើយជាមធ្យោបាយក្នុងការកសាងមូលដ្ឋានអប់រំ ដែលនឹងជួយឲ្យលទ្ធផលសិក្សារបស់កុមារមានភាពប្រសើរឡើង ហើយកាត់បន្ថយការបោះបង់ការសិក្សា។[5] ការអប់រំកុមារតូចមានភាពប្រសើរឡើងដោយមានកុមារអាយុ៥ឆ្នាំចំនួន៦៤.០៧% ទទួលបានការអប់រំក្នុងឆ្នាំសិក្សា២០១៤-២០១៥[6] បើប្រៀបធៀបជាមួយនឹងអត្រា៣៥%ក្នុងឆ្នាំ២០០៨-២០០៩។[7] ប៉ុន្តែទោះបីជាយ៉ាងនេះក្តី មានកុមារអាយុ៣ឆ្នាំប្រហែល ២០% និងកុមារអាយុ៤ឆ្នាំប្រហែល ៣០% ប៉ុណ្ណោះដែលទទួលបានការអប់រំសម្រាប់កុមារតូចក្នុងឆ្នាំសិក្សា២០១៤-២០១៥ ដូច្នេះជារួម ការចូលរៀនរបស់កុមារអាយុ៣-៥ឆ្នាំនៅមានកម្រិតទាបនៅឡើយ ជាពិសេសកុមារនៅតំបន់ជនបទ កុមារជនជាតិភាគតិច កុមារពិការ និងកុមារមកពីគ្រួសារក្រីក្រ។[8] ដើម្បីឲ្យការអប់រំកុមារតូចមានវិសាលភាពធំជាងមុនទាមទារឲ្យមានបទបញ្ញត្តិគាំទ្រ មូលនិធិពីរាជរដ្ឋាភិបាលច្រើនជាងមុន ការបង្កើនសមត្ថភាពគ្រប់គ្រងសេវាអប់រំកុមារតូច និងការបង្កើនសមត្ថភាពអប់រំរបស់គ្រូ។[9]

- **ការទទួលបានការអប់រំនៅថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ**

ការចុះឈ្មោះចូលរៀន វត្តមាន និងការបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យនៅតែជាបញ្ហាប្រឈម។ ជាឧទាហរណ៍ អត្រាពិតចូលរៀនថ្មីរបស់កុមារីនៅសាលាបឋមសិក្សារដ្ឋ និងឯកជនក្នុងឆ្នាំសិក្សា២០១៤-២០១៥សរុបទាំងអស់មាន ៩៥,៤% ដោយមានការធ្លាក់ចុះ៤,៦%។[10] ទោះបីជាមានអត្រានៃការសិក្សាខ្ពស់(៩៨,២% ក្នុងឆ្នាំសិក្សា ២០១៣-២០១៤) ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១៤ បានរកឃើញថាក្នុងចំណោមកុមារអាយុ៦-១១ឆ្នាំ មានតែកុមារី ៨១% និងកុមារា ៨៣% ប៉ុណ្ណោះកំពុងសិក្សា។[11]លើសពីនេះទៅទៀត អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាបានធ្លាក់ចុះពី ៨៤% មកដល់ ៨០,៦២% ក្នុងឆ្នាំ២០១៥ ហើយនៅក្នុងឆ្នាំ២០១៥ មានស្រុកចំនួន៩បន្ថែមទៀតដែលមានអត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាទាបជាង ៨០%។[12] ការព្យាករណ៍បង្ហាញថា និន្នាការធ្លាក់ចុះនេះនឹងនៅតែបន្តប្រសិនបើបញ្ហាប្រឈមនឹងការទទួលបានការសិក្សា និងគុណភាពនៃការសិក្សាមិនត្រូវបានដោះស្រាយ។[13]

បើទោះបីជាកុមារមានសិទ្ធិទទួលបានការអប់រំមូលដ្ឋាន រយៈពេល៩ឆ្នាំដោយឥតគិតថ្លៃក៏ដោយ ការសិក្សាស្រាវជ្រាវមួយនៅឆ្នាំ២០១២បានបង្ហាញថា អ្នកផ្តល់ចម្លើយជាសិស្ស ៥៣% និងមាតាបិតា ៦៧% បាននិយាយថា ពួកគាត់ត្រូវចំណាយប្រាក់ លើ សម្ភារសិក្សា ដែលគួរជាការទទួលខុសត្រូវរបស់សាលា និងក្រសួងអប់រំ។[14] ការចំណាយនេះមានតម្លៃប្រហែល ១១៩ដុល្លាសហរដ្ឋអាមេរិចក្នុងមួយឆ្នាំសម្រាប់សិស្សម្នាក់ [15] ដែលនេះជាកត្តាជម្រុញឲ្យមានការបោះបង់ចោលការសិក្សា ជាពិសេសសម្រាប់គ្រួសារក្រីក្រដែលមានកូនច្រើនទៅរៀន។

- **គុណភាពអប់រំ**

កម្រិតខ្ពស់នៃអត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា និងកម្រិតខ្ពស់នៃអត្រាបញ្ចប់ការសិក្សាមិនប្រាកដជាបង្ហាញពីគុណភាពនៃការអប់រំនោះឡើយ ហើយការចូលរៀនក្នុងប្រព័ន្ធអប់រំផ្លូវការ ក៏មិនធានាថាកុមារយកចិត្តទុកដាក់រៀនសូត្រដែរ។ វេទិការសេដ្ឋកិច្ចពិភពលោក បានឲ្យពិន្ទុគុណភាពអប់រំនៅបឋមសិក្សានៃប្រទេសកម្ពុជាត្រឹមតែ២.៩ លើ៧ពិន្ទុ (កម្ពុជាស្ថិតក្នុងលេខរៀង ទី១១៤ ក្នុងចំណោម ១៤០ប្រទេស)។[16] ហើយមានកុមារអាយុ ៣-៥ឆ្នាំ ត្រឹមតែចំនួន ៣០% ប៉ុណ្ណោះ ដែលមានការរីកលូតលាស់ផ្នែកការគិតលេខ និងអានអក្សរត្រឹមត្រូវតាមកម្រិត។ [17] ក្នុងការវាយតម្លៃអំណានជាតិថ្នាក់ដំបូងក្នុងឆ្នាំ២០១០ សិស្សថ្នាក់ទី១ ចំនួន ២/៣ មិនអាចអានបានសូម្បីតែមួយពាក្យ ហើយស្ទើរតែពាក់កណ្តាលនៃសិស្សថ្នាក់ទី២ មិនអាចអានបានសូម្បីតែមួយពាក្យ។[18] ការវាយតម្លៃជាតិថ្នាក់ទី៦ ក្នុង ឆ្នាំ២០១៥ បង្ហាញ

ថា មានសិស្សចំនួន ៤៥.៧% តែប៉ុណ្ណោះដែលបានប្រលងជាប់មុខវិជ្ជាអក្សរសាស្ត្រ ហើយ ៤៣,៤% ប្រលងជាប់មុខវិជ្ជាគណិតវិទ្យា។[19] អត្រាអក្ខរភាពទាបមួយផ្នែកគឺដោយសារការខ្វះឯកសារសម្រាប់អាន ជាពិសេសដោយសារតំបន់ជនបទមួយចំនួនមិនសូវមានសៀវភៅនិងឯកសារ។ ការសិក្សាមួយរបស់អង្គការទស្សនៈពិភពលោកក្នុងឆ្នាំ២០១៦ បានរកឃើញថា មានសាលារៀនប្រមាណ ២៥% ប៉ុណ្ណោះដែលមានសៀវភៅ និងធនធានសម្រាប់អានគ្រប់គ្រាន់ស្របតាមស្តង់ដារបស់ក្រសួងអប់រំដែលបានកំណត់ក្នុងឆ្នាំ ២០១១។[20]

ប្រៀបធៀបជាមួយប្រទេសជិតខាងរបស់ខ្លួន ប្រទេសកម្ពុជាមានផលធៀបសិស្ស-គ្រូ ៤៧:១ ដែលជាអត្រាខ្ពស់បំផុតនៅបណ្តាប្រទេសអាស៊ាន (ប្រៀបធៀបជាមួយប្រទេសឡាវ ២៦:១ វៀតណាម ១៩:១ និងភូមា ២៨:១) ដែលនេះអាចជះឥទ្ធិពលអវិជ្ជមានដល់គុណភាពអប់រំ។[21] លើសពីនេះទៅទៀត មានគ្រូបឋមសិក្សាត្រឹមតែ ៥៨% ប៉ុណ្ណោះ ដែលបានរៀនចប់ថ្នាក់ទី១២ ដែលធ្វើឲ្យសមត្ថភាពរ៉ាប់រងការងារវិជ្ជាជីវៈ និងជំនាញគរុកោសល្យរបស់ពួកគេនៅមានកម្រិត។[22]

ម៉ោងសិក្សាក្នុងប្រទេសកម្ពុជាគឺ ៦៨៤-៧៦០ម៉ោងក្នុង មួយឆ្នាំសិក្សា [23] ដែលជាតួលេខមួយទាបជាងអត្រាអន្តរជាតិ ៨៥០-១០០០ម៉ោង ក្នុងមួយឆ្នាំសិក្សា។[24] គុណភាពនៃការអប់រំក្នុងប្រទេសកម្ពុជាក៏ត្រូវបានបន្ថយបង្អាក់ដោយការបាត់បង់នូវចំនួនម៉ោងបង្រៀនក្រៅផ្លូវការដោយជាមធ្យម ក្នុងឆ្នាំ២០១៣ ចំនួនម៉ោងសិក្សា ២៧% (៥០,៥ថ្ងៃ) ត្រូវបានបាត់បង់ដោយការឈប់សម្រាកបន្ថែម អវត្តមានរបស់គ្រូ និងការបង្រួញម៉ោងសិក្សា។[25]

## ភាពខ្វះចន្លោះក្នុងការអនុវត្តគោលនយោបាយអប់រំ

ប្រទេសកម្ពុជាមានក្របខណ្ឌគោលនយោបាយទូលំទូលាយល្អសម្រាប់ការអប់រំកុមារ។ ប៉ុន្តែមានភាពខ្វះចន្លោះគួរឲ្យចាប់អារម្មណ៍ រវាងគោលនយោបាយ និងការអនុវត្តជាក់ស្តែង។ ជាឧទាហរណ៍ ទោះបីជាគោលនយោបាយសាលាកុមារមេត្រីត្រូវបានដាក់ឲ្យអនុវត្តតាំងពីឆ្នាំ២០០៧មកក៏ដោយ ក៏គោលនយោបាយនេះមិនត្រូវបានអនុវត្តពេញលេញនៅឡើយ ដោយសម្ភារបរិក្ខាមូលដ្ឋានដែលបង្កើនការទៅសាលារបស់កុមារ ដូចជាបង្គន់អនាម័យ កន្លែងលាងដៃ និងទឹកស្អាត មិនមានភាពល្អប្រសើរឡើងនោះឡើយ។[26] បច្ចុប្បន្នសាលារៀនជិត ៥០% ខ្វះការផ្គត់ផ្គង់ទឹក ហើយ ៣០% ខ្វះបង្គន់អនាម័យ។[27] ការពុំមានសម្ភារបរិក្ខាទាំងនេះនាំឲ្យមានការបោះបង់ចោលការសិក្សា និងអវត្តមាន ជាពិសេសសម្រាប់កុមារី។

លើសពីនេះទៅទៀតការសិក្សាស្រាវជ្រាវថ្មីៗនេះបានបង្ហាញថាសាលារៀនមិនប្រាកដថាជាកន្លែងមានសុវត្ថិភាពសម្រាប់កុមារឡើយ។ សិស្ស ៧៣% (កុមារា ៧៦% និងកុមារី ៧០%) និយាយថាពួកគេធ្លាប់ទទួលរងការរំលោភបំពានយ៉ាងហោចណាស់មួយប្រភេទនៅសាលារៀន។ សិស្សចំនួនពាក់កណ្តាល ទាំងកុមារា និងកុមារីបានវាយតម្លៃសាលារបស់គេ (ទាំងថ្នាក់រៀន និងទីធ្លាសម្រាប់ក្មេងលេង) ថា "មិនមានសុវត្ថិភាព" ឬ "មិនសូវមានសុវត្ថិភាព"។[28] លើសពីនេះទៅទៀត កុមារីច្រើនជាងមួយភាគបួន ដែលមានអាយុ ១៣-១៧ ឆ្នាំ ដែលធ្លាប់ទទួលរងការរំលោភបំពាន និយាយថា ការរំលោភបំពានផ្នែកផ្លូវភេទបានកើតឡើងដំបូងបំផុតនៅសាលារៀន។[29] បញ្ហាទាំងអស់នេះរឹតតែតម្រូវឲ្យក្រសួងអប់រំរួសរាន់អនុវត្តឲ្យបានពេញលេញនូវ*គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន* ដែលទើបតែបានអនុម័តនាពេលថ្មីៗនេះ។

ចំនុចចុងក្រោយ គោលនយោបាយស្តីពីការអប់រំកុមារពិការបានអនុម័តតាំងពីឆ្នាំ២០០៨មកម្ល៉េះ ប៉ុន្តែការទទួលបានការអប់រំរបស់កុមារពិការ ជាពិសេសកុមារពិការធ្ងន់ធ្ងរនៅមានកម្រិតនៅឡើយ។ នេះក៏ដោយសារមានការខ្វះខាតគ្រូមានសមត្ថភាព ធនធានសម្រាប់បង្រៀនកុមារពិការ សម្ភារសម្របសម្រួលសម្រាប់កុមារពិការ និងអាគារដែលបង្កលក្ខណៈងាយស្រួលចេញចូលសម្រាប់កុមារពិការ។[30] គេប៉ាន់ប្រមាណថាកុមារពិការប្រហែលជា ២៥% ក្នុងប្រទេសកម្ពុជា មិនដែលបានទទួលការអប់រំណាមួយឡើយ។[31]

**ជាការឆ្លើយតបនឹងបញ្ហាអប់រំក្នុងប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោក សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យដោះស្រាយបញ្ហាការទទួលបានការអប់រំ និងគុណភាពអប់រំដោយ៖**

- បង្កើតនូវក្របខណ្ឌគតិយុត្តិអន្តរក្រសួងសម្រាប់ការអប់រំកុមារតូចដោយមានក្រសួងអប់រំជាអ្នកទទួលខុសត្រូវចម្បង ហើយដាក់ការចំណាយនេះក្នុងថវិការបស់ក្រសួង។ បន្ទាប់មកទៀត ពង្រីកវិសាលភាពការអប់រំកុមារតូចដោយយកចិត្តទុកដាក់ជាសំខាន់ចំពោះតំបន់មិនសូវមានឱកាសទទួលបានការសិក្សា។

- ផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀនអំពីការអប់រំបរិយាប័ន្ន និងវិធីសាស្ត្រគរុកោសល្យដើម្បីជួយកុមារពិការនៅក្នុងការសិក្សា។

- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីបង្កើតគោលការណ៍ណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ដំបូងអំពីរបៀបបង្រៀនដើម្បីឲ្យកុមារទទួលបានជំនាញមូលដ្ឋានផ្នែកអក្សរនិងលេខ។

- ធានាថាសាលារៀនជាកន្លែងមានសុវត្ថិភាពតាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ*គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន* ហើយផ្តោតលើការបណ្តុះបណ្តាលគ្រូបង្រៀនអំពីការអប់រំបែបវិជ្ជមាន ព្រមទាំងពង្រឹងការអនុវត្ត *សមាសភាពទី ៣ សាលារៀនសុវត្ថិភាព*(២០១៣) ដែលស្ថិតក្នុងក្របខណ្ឌ *គោលនយោបាយសាលាកុមារមេត្រី*(២០០៧) របស់ក្រសួងអប់រំ។

- ធ្វើឲ្យមានភាពប្រសើរឡើងនូវការឆ្លើយតប និងគណនេយ្យភាពរបស់អ្នកធ្វើការសម្រេចចិត្តថ្នាក់មូលដ្ឋាន ដោយគាំទ្រយ៉ាងពេញទំហឹងនូវការបង្កើនការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម(ISAF) ដែលជាផ្នែកមួយនៃកំណែទម្រង់វិសហមជ្ឈការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

---

[1] UNICEF. *Education.* Available at http://www.unicef.org/cambodia/3.Education.pdf.
[2] RGC. *Constitution of Cambodia (amended in 1999).*
[3] MOEYs (2014). *National Education for All Committee: The National Education for All 2015 Review Report.*
[4] UNICEF. *Education.* Available at http://www.unicef.org/cambodia/3.Education.pdf.
[5] NEP (2008). *The Impact of Preschool on Early Childhood Education in Cambodia: A Study of Six NGO-Sponsored Preschools in Battambang, Kampong Chhnang and Phnom Penh.*
[6] MoEYS (2016). *Education Congress – (Report on) MoEYS performance in the academic year 2014-2015 and goals for the academic year 2015-2016.*
[7] MoEYS. *Early Childhood Education.* Available at http://www.moeys.gov.kh/en/early-childhood-education.html. See also ESWG (2015). *Joint Government-Development Partners Cambodia Education Sector Review.*
[8] MoEYS (2016). *Education Congress – p. 18.*
[9] MoEYS (2015). *The National Education for All: 2015 Review Report.*
[10] MoEYS (2016). *Education Congress document.*
[11] National Institute of Statistics, Directorate General for Health, and ICF International (2015). *Cambodia Demographic and Health Survey (CDHS) 2014.*
[12] MoEYS (2016). *Education Congress report.*
[13] ESWG (2015). *Joint Government-Development Partners Cambodia Education Sector Review.*
[14] NEP (2012). *Promoting Rights in Schools: The State of Children's Rights in Cambodian Primary Schools.*
[15] *Ibid.*
[16] WEF (2015). *Global Competitiveness Report, World Economic Forum,* available at http://reports.weforum.org/global-competitiveness-report-2015-2016/economies/#economy=KHM
[17] CDHS (2014).
[18] USAID (2015). *Data for Education Programming in Asia and Middle East: Assessment of Early Grade Reading in the Education Sector in Cambodia.*
[19] MoEYS (2015). *Results of Grade Six Student Achievement from the National Assessment in 2013.*
[20] World Vision (2016). *Current Situation & Use of Primary School Libraries: A snapshot across 5 provinces in Cambodia.*
[21] UNDP (2015). *Human Development Report 2015.*
[22] CDRI (2015). *Cambodia Education 2015 - Employment and Empowerment.*
[23] MoEYS (2004): *Policy for Curriculum Development (2005-2009).*
[24] NEP (2015): *Teaching Hours in Primary Schools in Cambodia.*
[25] *Ibid.*
[26] See UNESCO, VSO, NEP (2014). *Right to Education in Cambodia: Community Level Research* as well as ESWG (2015). *Joint Government-Development Partners Cambodia Education Sector Review.*
[27] *Ibid.*
[28] International Center for Research on Women (ICRW) & Plan International (2014). *Are Schools Safe and Gender Equal Spaces: Finding from a Baseline Study of School Related Gender-based Violence in Five Countries in Asia.*
[29] Ministry of Women's Affairs, UNICEF Cambodia, US Centers for Disease Control and Prevention (2014). *Findings from Cambodia's Violence Against Children Survey 2013.*
[30] Plan International (2014). *Vulnerable and Marginalised Children's Access to, Learning and Participation in School: Understanding the Challenges.*
[31] NGOCRC (2013). *UPR Submission on Cambodian Child Rights.*